# ជំងឺ COVID-19

## បញ្ហា Myocarditis និងបញ្ហា Pericarditis

**បញ្ហា Myocarditis (ម៉ាយអូខាដាយធីស) គឺជាការរលាកសាច់ដុំបេះដូង។ បញ្ហា Pericarditis (ភែរីខាដាយធីស) គឺជាការរលាកស្រទាប់ខាងក្រៅនៃបេះដូង។**

- បញ្ហាទាំងពីរនេះត្រូវបានបង្កឡើងដោយការឆ្លើយតបតាមធម្មជាតិរបស់រាងកាយទៅនឹងការឆ្លងមេរោគ ឬកត្តាបង្កផ្សេងទៀត។ ហេតុផលទូទៅផ្សេងៗរួមមានការឆ្លងមេរោគរស់ (bacterial infection) ការឆ្លងមេរោគជំងឺ (viral infection) និងបញ្ហាសុខភាពនានាដូចជាជំងឺបំផ្លាញកោសិកាសរីរាង្គដោយប្រព័ន្ធភាពស៊ាំ (autoimmune) ផងដែរ។ ការឆ្លងជំងឺ COVID-19 ព្រមទាំងថ្នាំបង្ការទាំងឡាយអាចបង្កឱ្យមានបញ្ហាបេះដូងទាំងនេះ ផងដែរ។
- រោគសញ្ញានានាអាចរួមមានឈឺទ្រូង ដកដង្ហើមខ្លីៗ មានអារម្មណ៍ថាបេះដូងលោតញាប់ ឬលោតខុសធម្មតា ឬលោតខ្លាំង មានអារម្មណ៍ទន់ខ្សោយឬអត់កម្លាំងខ្លាំង ហើយនិងការបាត់បង់ចំណង់អាហារ។

**បញ្ហា Myocarditis បញ្ហា Pericarditis ហើយនិងថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ**



- មនុស្សទាំងឡាយកម្រនឹងកើតមានបញ្ហារលាកសាច់ដុំបេះដូង (myocarditis) ឬបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូង (pericarditis) ណាស់ បន្ទាប់ពីការចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna ឬក៏ប្រភេទ Novavax រួចនោះ។
- ជាទូទៅ រោគសញ្ញានានាចាប់ផ្តើមកើតមានក្នុងរយៈពេល ពីរឬបីថ្ងៃបន្ទាប់ពីការចាក់ថ្នាំបង្ការ។ មនុស្សភាគច្រើនមានអារម្មណ៍ធូរស្បើយយ៉ាងឆាប់រហ័ស ដោយការប្រើប្រាស់ថ្នាំពេទ្យ និងការសម្រាកព្យាបាល។
- យុវវ័យភេទប្រុស និងមនុស្សពេញវ័យនៅក្មេងទំនងជានឹងកើតមានបញ្ហាទាំងនេះជាងគេ។ ការរង់ចាំរយៈពេល 8 សប្តាហ៍រវាងដូសទី 1 និងដូសទី 2 នៃថ្នាំបង្ការនេះអាចកាត់បន្ថយហានិភ័យបាន។

**ហានិភ័យផ្សេងៗទៅដល់បេះដូងដោយសារការចាក់ថ្នាំបង្ការជំងឺ COVID-19 មានកម្រិតទាបជាងហានិភ័យផ្សេងៗដោយសារការឆ្លងជំងឺ COVID-19 ណាស់។**

- ទាំងថ្នាំបង្ការជំងឺ COVID-19 និងការឆ្លងជំងឺ COVID-19 អាចបង្កើនហានិភ័យនៃការកើតមានបញ្ហារលាកសាច់ដុំបេះដូង និងបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូងបាន។ ប៉ុន្តែការឆ្លងជំងឺ COVID-19 ក៏អាចបង្កើនហានិភ័យនៃការកើតមានបញ្ហាបេះដូងផ្សេងៗទៀត ដូចជារោគសញ្ញាសរសៃឈាមបេះដូងលក្ខណៈធ្ងន់ធ្ងរ (acute coronary syndrome) បញ្ហាគាំងបេះដូង (ការរួមសាច់ដុំបេះដូងដោយសារការស្ទះសរសៃឈាម /myocardial infarction) បញ្ហាខ្សោយបេះដូង (heart failure) និងបញ្ហាចង្វាក់បេះដូងដើរមិនត្រឹមត្រូវ (arrhythmia) ផងដែរ។
- សម្រាប់ព័ត៌មានបន្ថែម សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ឬក៏ចូលទៅកាន់គេហទំព័រ៖ បញ្ហារលាកសាច់ដុំបេះដូង និងបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូង បន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ mRNA របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។